# តើសមាជិកសភារូបណា នឹងក្លាយជាម្ចាស់ពានរង្វាន់សមាជិកសភាប្រចាំឆ្នាំ ២០២៣ របស់សហភាពអន្តរសភា?




Inter-Parliamentary Union For democracy. For everyone.

**ថ្ងៃអាទិត្យ ១២កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២ ខែមេសា ឆ្នាំ២០២៣**

ការចុះឈ្មោះបេក្ខជនដែលត្រូវបានជ្រើសតាំង សម្រាប់ប្រកួតប្រជែងយកពានរង្វាន់Cremer-Passy Prize ឆ្នាំ២០២៣ របស់សហភាពអន្តរសភា(IPU) បានចាប់ផ្តើមបើកហើយ នៅពេលនេះ។ បេក្ខជនដែលត្រូវបានជ្រើសតាំងសម្រាប់ប្រជែងយកពានរង្វាន់នេះ ត្រូវតែជាសមាជិកសភាក្នុងតំណែង ដែលបានរួមចំណែកយ៉ាងខ្លាំងក្លាក្នុងការការពារ(Defence)និងលើកកម្ពស់(Promote) គោលដៅរបស់សហភាពអន្តរសភា(IPU's objectives) និងជាបុគ្គលដែលបានរួមចំណែកក្នុងការកសាងភពផែនដីមួយ ដែលមានសមធម៌ជាងមុន សន្តិភាពជាងមុន ចីរភាពជាងមុន និងសាមគ្គីភាពជាងមុន។

ពានរង្វាន់Cremer-Passy Prize ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០២២ ហើយក្នុងឆ្នាំដំបូង(ឆ្នាំ ២០២២)ពានរង្វាន់នេះ ត្រូវបានប្រគល់ជូន លោកស្រីCynthia Lopez Castroសមាជិកសភាជាន់ទាបនៃសហរដ្ឋម៉ិកស៊ិក និងប្រធានសភានិងសមាជិកសភាទាំងអស់នៃប្រទេសអ៊ុយក្រែន នៅក្នុងសន្និបាតសហភាពអន្តរសភាលើកទី១៤៥ ក្នុងរដ្ឋធានីគីហ្កាលី នៃសាធារណរដ្ឋរវ៉ាន់ដា។

សម្រាប់ឆ្នាំនេះ បើយោងទៅតាមការចាប់ផ្តើមកាលពីពេលថ្មីៗនេះ របស់សហភាពអន្តរសភានូវយុទ្ធនាការថ្មីមួយស្តីពីអាកាសធាតុ ដែលមានឈ្មោះថាសភាសម្រាប់ភពផែនដី (Parliament for the Planet) បេក្ខជនចូលរួមក្នុងការប្រកួតប្រជែងឆ្នាំនេះ គួរតែជាបេក្ខជន ដែលមានប្រវត្តិអស្ចារ្យបំផុត(First-class record)ក្នុងការងារសភា ផ្នែកបម្រែបម្រួលអាកាសធាតុ។ បេក្ខជន ដែលមានបំណងចូលរួមការប្រកួតប្រជែងនេះ ត្រូវចូលតាមច្រកក្រុមភូមិសាស្ត្រនយោបាយ(Geopolitical Groups)ទាំង៦ក្រុម របស់សហភាពអន្តរសភា ហើយក្រុមនីមួយៗនៃក្រុមទាំង៦នេះ នឹងចម្រាញ់យកបេក្ខជន២នាក់(១នាក់ ជាបេក្ខជនពេញសិទ្ធិ និង១នាក់ទៀត ជាបេក្ខជនបម្រុង) ដើម្បីប្រកួតប្រជែងបន្តទៀត។ ក្រុមភូមិសាស្ត្រនយោបាយទាំងអស់ ត្រូវបំពេញទម្រង់ស្នើសុំចូលរួមប្រកួតប្រជែងដែលបានផ្តល់ជូន និងភ្ជាប់ជាមួយនូវលិខិតអមមួយ រៀបរាប់អំពីមូលហេតុដែលបេក្ខជនរូបនោះ សមនឹងទទួលបានពានរង្វាន់។ ទម្រង់ស្នើសុំ និងលិខិតអម ត្រូវផ្ញើមកអ៊ីម៉ែលpress@ipu.org យ៉ាងយូរត្រឹមថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣។ បេក្ខជនជ័យលាភី នឹងត្រូវប្រកាសឈ្មោះនៅក្នុងសន្និបាតសហភាពអន្តរសភា លើកទី១៤៧ នៅចុងឆ្នាំនេះ។

ឈ្មោះពានរង្វាន់នេះ គឺយកតាមឈ្មោះរបស់សមាជិកសភា២រូប គឺលោក Frédéric Passy និង Sir William Randal Cremer ដែលជាអ្នកបង្កើតសហភាពអន្តរសភាក្នុងឆ្នាំ១៨៨៩៕

*ព័ត៌មានពីសហភាពអន្តរសភា ០២-០៤-២៣- តូនី*

ប្រែសម្រួលពីៈ https://www.ipu.org/news/news-in-brief/2023-03/who-will-be-mp-year

# Who will be the MP of the year?

Tue, 21/03/2023 - 10:28




Nominations are now open for the 2023 edition of the Cremer-Passy Prize.

The prize is open to sitting parliamentarians who make an outstanding contribution to the defence and promotion of the IPU's objectives, as well as those "who contribute to a more united, peaceful, sustainable and equitable world."

In 2022, the inaugural prize was exceptionally awarded to two nominees, one woman and a group led by a man, to underscore the importance of gender equality at the IPU. Ms. Cynthia Lopez Castro of Mexico, and the Chairman and all the Members of the Verkhovna Rada of Ukraine were awarded the prize at the $145^{th}$ IPU Assembly in Kigali, Rwanda.

This year, following the IPU's recent launch of its new climate campaign Parliaments for the Planet, nominees should have a first-class track record of parliamentary action on climate change.

Nominations should go through the IPU's six geopolitical groups who should submit one candidate from their region with a second nomination as an alternate. The geopolitical groups should fill in the specific application form below and provide a cover letter setting out the reasons why the parliamentarians deserve the award. Forms and letters should be sent to press@ipu.org **by 30 April.**

The winners will be announced at the $147^{th}$ IPU Assembly later in the year.

The prize is named after the two IPU founders, parliamentarians, Frédéric Passy and Sir William Randal Cremer, who created the IPU in 1889.

- Submission form

For more information watch the video below. Read the rules and regulations here

ថ្នាក់ដឹកនាំសន្និបាតសភាអង្គការណាតូ ពិភាក្សាគ្នាអំពីការគាំទ្រប្រទេសអ៊ុយក្រែន ក្នុងរាជធានីអូស្លូ៖

គណៈកម្មាធិការអចិន្ត្រៃយ៍របស់សន្និបាតសភាអង្គការណាតូ ដែលជាក្រុមអភិបាលរបស់សន្និបាតនេះ បានបើកកិច្ចប្រជុំនិទាឃរដូវប្រចាំឆ្នាំ របស់ខ្លួនក្នុងរាជធានីអូស្លូ នៃព្រះរាជាណាចក្រន័រវែស កាលពីថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣។ កិច្ចប្រជុំដែលធ្វើជាម្ចាស់ផ្ទះដោយគណៈប្រតិភូសភាន័រវែស ដែលដឹកនាំដោយសមាជិកសភាTrond Helleland មួយនេះ មានការចូលរួមពីសមាជិកសភាជាង៤០រូប ពី៣០ ប្រទេសជាសម្ព័ន្ធមិត្តអន្តរអាត្លង់ទិក បូកនិងព្រះរាជាណាចក្រស៊ុយអែត តបតាមការអញ្ជើញរបស់អង្គការណាតូ។ នៅក្នុងកិច្ចសន្ទនាជាមួយមន្ត្រីជាន់ខ្ពស់ប្រទេសអ៊ុយក្រែនដែលសមភាគីរបស់ខ្លួន សមាជិកសភាដែលចូលរួមក្នុងកិច្ចប្រជុំនេះ បានគូសបញ្ជាក់សាជាថ្មីអំពីការគាំទ្រឥតងាករេរបស់សន្និបាតនេះ ចំពោះប្រទេសអ៊ុយក្រែន និងបានពិភាក្សាគ្នាជាលើកដំបូងអំពីអនុសាសន៍សម្រាប់បង្កើនល្បឿននៃ ការសម្របខ្លួនរបស់អង្គការណាតូ ក្នុងស្ថានភាពបច្ចុប្បន្ន...៕

https://www.nato-pa.int/news/oslo-assembly-leadership-discusses-support-ukraine-nato-adaptation

.

Hosted by the Norwegian delegation, led by Trond Helleland, the meeting brought together over 40 lawmakers from the 30-nation transatlantic Alliance, as well as NATO invitee Sweden. Parliamentarians reaffirmed the Assembly's unwavering support for Ukraine in dialogue with their Ukrainian counterparts and had a first discussion on recommendations for accelerating NATO's adaptation.

# In Oslo, Assembly leadership discusses support to Ukraine, NATO adaptation

27 March 2023

The NATO Parliamentary Assembly's (NATO PA) Standing Committee, the Assembly's governing body, held its annual spring meeting in Oslo, Norway on 26 March.

Hosted by the Norwegian delegation, led by Trond Helleland, the meeting brought together over 40 lawmakers from the 30-nation transatlantic Alliance, as well as NATO invitee Sweden. Parliamentarians reaffirmed the Assembly's unwavering support for Ukraine in dialogue with their Ukrainian counterparts and had a first discussion on recommendations for accelerating NATO's adaptation.

Connected from Ukraine, Ruslan Stefanchuk, Chairman of the Verkhovna Rada, and Yehor Cherniev, Head of the Ukrainian Delegation to the NATO PA, both updated the Standing Committee about the latest developments and outlined the country's needs for increased assistance.

"Our parliaments and this Assembly continue to play their part in mobilising support. We will not relent in our efforts," NATO PA President Joëlle Garriaud-Maylam (France) underlined. "We remain united and resolute in standing with Ukraine for as long as it takes to prevail." The Standing Committee discussed further assistance and support to Ukraine.

"The war in Ukraine is a watershed moment for our continent. And one year into the war, we see profound implications for my country, for Europe and the world," Norway's Prime Minister Jonas Gahr Støre told the Standing Committee.

The members had a first discussion to develop the Assembly's recommendations for the Summit of Heads of State and Government which will take place in Vilnius, Lithuania on 11-12 July. The Assembly's final input will be agreed during its spring session in Luxembourg at the end of May.

Following President Putin’s announcement the previous day that he has sent dual-capable Iskander missile systems and plans to station tactical nuclear weapons into Belarus, members denounced Russia’s ongoing, irresponsible nuclear sabre-rattling.

During their one-day meeting, the Assembly’s leaders also reviewed recent development on the accession of Sweden and Finland, discussed developments in Tunisia, considered the Review of the Assembly’s Consideration of Gender in 2022, published earlier today, and discussed other statutory matters.

The NATO PA serves as the consultative interparliamentary organisation for the North Atlantic Alliance. It is institutionally separate and independent from NATO.

The Standing Committee is the Assembly’s governing body, composed of the Head of each member delegation, the President, the Vice-Presidents, the Treasurer and the Chairpersons of the Assembly's Committees and of the Mediterranean and Middle East Special Group.